# ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និង អតីតយុទ្ធជន

*រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ១៩៩៤*

## ប្រកាសលេខ ២២ ស.ក.អ
## ស្តីពី
## នីតិវិធីនៃការដោះស្រាយវិវាទបុគ្គល

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ការងារ

## សំរេច

**ប្រការ ១ :** ក្នុងការជំរះវិវាទការងារ មុននឹងប្តឹងទៅតុលាការ គ្រប់រឿងវិវាទបុគ្គលត្រូវតែភាគីណាមួយប្តឹងទៅអធិការការងារ ឬ អភិបាលការងារ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន ។

នាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ស្ថិតនៅអគារលេខ ២៨ ផ្លូវ សម្តេចព្រះធម្មលិខិតអ៊ុត សង្កាត់ជ័យជំនះខ័ណ្ឌដូនពេញមានសមត្ថកិច្ចទទួលខុសត្រូវផ្សះផ្សាវិវាទការងារនៅរាជធានីភ្នំពេញ ។

អធិការដ្ឋានសង្គមកិច្ចការងារ និងអតីតយុទ្ធជន ខេត្ត ក្រុងដទៃទៀតមានសមត្ថកិច្ចទទួលខុសត្រូវផ្សះ ផ្សាវិវាទការងារនៅខេត្ត ក្រុងរៀងខ្លួន ។

**ប្រការ ២ :** ក្រោយពីបានទទួលបណ្តឹងពីភាគីណាមួយ អធិការការងារ ឬអភិបាលការងារត្រូវធ្វើលិខិតអញ្ជើញទៅភាគីទាំងអស់មកផ្តល់ព័ត៌មាន និងឯកសារជាភស្តុតាងនានាដែលខ្លួនចង់បានដើម្បីផ្សះផ្សាវិវាទអោយបានសម្រុះ ។

ការសាកសួរពត៌មានបន្ថែមនេះត្រូវធ្វើឡើងមួយភាគីម្តងដាច់ដោយឡែកពីគ្នា ។ គ្រប់ពេលសាកសួរពត៌មានបន្ថែមត្រូវធ្វើកំណត់ហេតុទុកជាឯកសារដោយមានចុះហត្ថលេខាអធិការ ឬ អភិបាលការងារនិងភាគីដែលផ្តល់ពត៌មាននោះផង ។

**ប្រការ ៣ :** បើភាគីដើមចោទ ឬ តំណាងនៃជននេះ មិនព្រមអញ្ជើញទៅផ្តល់ពត៌មានបន្ថែមជូនអធិការ ឬ អភិបាលការងារតាមកាលកំណត់ ឬ ក្នុងរយៈពេល ៣ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកំណត់ " គិតតែថ្ងៃធ្វើការ " ដោយគ្មានមូលហេតុសមស្របទេនោះ ពាក្យបណ្តឹងនោះត្រូវទុកជាមោឃៈ ។

បើភាគីចុងចោទ ឬតំណាងនៃជននេះមិនព្រមចូលបង្ហាញខ្លួនក្នុងវេលាឬដោយ មូលហេតុដូចមានកំណត់ក្នុងកថាខ័ណ្ឌទី១នៃប្រការ ៣នេះ រឿងវិវាទត្រូវចាត់ទុកថាមិនសះជា ហើយត្រូវចាត់ទុកថាភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង ។

**ប្រការ ៤ :** បន្ទាប់ពីបានទទួលពត៌មានសព្វគ្រប់អស់ហើយ អធិការ ឬ អភិបាលការងារ ត្រូវធ្វើលិខិត អញ្ជើញម្តងទៀតអោយភាគីទាំងសងខាងចូលរួមប្រជុំជាមួយគ្នា ដើម្បីធ្វើការផ្សះផ្សា ។

ភាគីវិវាទអាចអោយគេជួយអម ឬ អោយគេតំណាងខ្លួនបាន ។

បើភាគីដើមចោទ ឬ តំណាងនៃជននេះមិនចូលរួមប្រជុំតាមកាលកំណត់ ហើយគ្មាន បញ្ជាក់ មូលហេតុសមស្របទេ ពាក្យប្តឹងត្រូវចាត់ទុកជាមោឃៈ ។

បើភាគីចុងចោទ ឬតំណាងនៃជននេះមិនចូលរួមប្រជុំតាមកាលកំណត់ហើយគ្មានបញ្ជាក់មូលហេតុសមស្របទេរឿងវិវាទត្រូវចាត់ទុកថា មិនសះជា ហើយត្រូវចាត់ទុកថា ភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង ។

**ប្រការ ៥ :** លិខិតអញ្ជើញដែលមានចែងក្នុងប្រការ ២ និងប្រការ ៤ ត្រូវធ្វើផ្ញើនភាគីតាមសំបុត្រអនុសិដ្ឋដែលមានហត្ថលេខាចុះបញ្ជាក់ថាបានទទួលហើយ ។

**ប្រការ ៦ :** ជនទាំងឡាយនិងអាចជួយអម ឬ ធ្វើជាតំណាងរបស់ភាគីវិវាទបាន លុះត្រាតែជននោះជា មនុស្សពេញវ័យដែលច្បាប់ទទួលស្គាល់ ហើយអាចសំរេចកិច្ចការបានផង ។

**ប្រការ ៧ :** ត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំផ្សះផ្សាដោយមានបញ្ជាក់ច្បាស់លាស់ពីការយល់ព្រម ឬ មិនយល់ព្រមសះជានឹងគ្នា ។ កំណត់ហេតុនោះត្រូវចុះហត្ថលេខាដោយអធិការ ឬ អភិបាលការងារព្រមទាំងហត្ថលេខារបស់ភាគីទាំងសងខាងនិងត្រូវចម្លងចែកភាគីផង ។

**ប្រការ ៨** ក្នុងករណីសះជាគ្នា បើភាគីណាមួយយកកំណត់ហេតុនេះទៅអនុវត្ត ភាគី នោះត្រូវទៅប្តឹងចាងហ្វាង តុលាការការងារ ឬ បើពុំមានតុលាការនេះទេ ត្រូវទៅប្តឹងប្រធានតុលាការខេត្ត ក្រុងសុំអោយ ចេញ ដីកាសំរេចអោយចុះ លើកំណត់ហេតុរបស់អធិការការងារនូវរូបមន្តបង្គាប់អោយប្រតិបត្តិកំណត់ ហេតុនោះតែម្តង ។ ការប្រតិបត្តិកំណត់ហេតុត្រូវប្រព្រឹត្តទៅឬូរហែដូចជាសាលក្រមតុលាការការ ងារដែរ ។

ប្រធានតុលាការដែលមានសមត្ថកិច្ចនោះ គឺប្រធានតុលាការខេត្ត ក្រុង ដែលកំណត់ហេតុនៃការ ផ្សះផ្សាបានធ្វើនិងចុះហត្ថលេខា ។

**ប្រការ ៩ :** ក្នុងករណីមិនសះជា ដោយរាប់ទាំងការមិនសះជាដែលមានកំណត់ក្នុងប្រការ ៣ និងប្រការ ៤ ខាង លើផង អធិការឬ អភិបាលការងារត្រូវជំរាបទៅភាគីអំពីសិទ្ធិរបស់ភាគីដើមចោទដែលអាចធ្វើ ពាក្យប្តឹងជាបន្តទៅតុលាការមានសមត្ថកិច្ចទៅតាមបែបបទ ដែលមានកំណត់ក្នុងច្បាប់ ។ អធិការ ឬ អភិបាលការងារត្រូវផ្តល់ជូនទៅភាគីនូវកំណត់ហេតុនានាខាងលើ ដើម្បីបំពេញសំណុំ រឿងនៃការ ប្តឹងបន្តនោះផង ។

**ប្រការ ១០ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ស៊ុយ សែម**

***

## ប្រកាសលេខ ២៣ សករ

## ស្តីពី

## ថ្លៃឈប់បុណ្យដែលក្រុមហ៊ុនត្រូវបង់ប្រាក់ឈ្នួល

## រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣